# សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ: ........ ស.ខ.ក.ក.

## សេចក្តីអំពាវនាវ

ខ្ញុំព្រះករុណាខ្ញុំ ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជា-ធិបតេយ្យ(iCambodia_យុវជនដើម្បីប្រជាធិបតេយ្យ, I Love Cambodia Hot News, យុវជនខ្មែរមហានគរ, ក្លឹបសំឡេងយុវជនខ្មែរ_អន្តរជាតិ, យុវជន ដើម្បីសន្តិភាព, ចលនាយុវជនស្វ័យតប្រជាធិបតេយ្យខ្មែរ និងចលនាប្រជាធិបតេយ្យជាតិនិយម) សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ! សូមគោរពជនរួមជាតិ យុវជន យុវនារីជាទីស្នេហា !

ពេលនេះ ជាពេលវេលាមួយដែលប្រជាជាតិខ្មែរ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ត្រូវរួបរួមសាមគ្គីជាធ្លុងមួយ ដើម្បីការពារប្រវត្តិសាស្ត្រខ្មែរ ការពារកិត្តិយសពូជសាសន៍ខ្មែរ និងការពារទឹកដីខ្មែរឲ្យបានគង់វង្ស។ ការនិយាយបំភ្លៃការពិតនៃប្រវត្តិសាស្ត្រខ្មែរ ការមិនទទួលយកញត្តិ ការមិនព្រមសុំទោសឬមិនព្រមទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រខ្មែរ របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម គឺជាភេរវសញ្ញាប្រាប់ប្រជារាស្ត្រខ្មែរឲ្យដឹងច្បាស់ថា រដ្ឋាភិបាលវៀតណាមនៅតែចិញ្ចឹមចិត្តវាតទីយកទឹកខ្មែរ មើលងាយប្រជារាស្ត្រខ្មែរនិងក្រឡៃប្រវត្តិសាស្ត្រខ្មែរដោយចេតនាយ៉ាងពិតប្រាកដ។

រដ្ឋាភិបាលវៀតណាម គ្មានចេនាល្អ ក្នុងការរឹតចំណងមិត្តភាពកម្ពុជា-វៀតណាម ក្នុងស្មារតីភាតរភាពប្រកបដោយសមធម៌ ក្នុងឋានៈជាប្រទេសជិតខាងល្អនោះទេ ជាក់ស្តែងដូចពេលនេះ រដ្ឋាភិបាលវៀតណាមហ៊ានបំភ្លៃប្រវត្តិសាស្ត្រខ្មែរទាំងងងើលដោយឥតអៀនខ្មាស់ ហើយថែមទាំងនិយាយដដែលៗថា មិនខ្វល់ និងញត្តិ មិនខ្វល់និងការធ្វើបាតុកម្មរបស់ប្រជារាស្ត្រខ្មែរ របស់ព្រះសង្ឃខ្មែរនោះទេ នៅតែរក្សាជំហរមិនសុំទោសប្រជារាស្ត្រខ្មែរដដែល។

សេចក្តីដូចបានប្រគេន និងជំរាបជូនខាងលើ យើងខ្ញុំ សូមអំពាវនាវព្រះករុណាគ្រប់ព្រះអង្គបងប្អូនរួមជាតិទូទាំងប្រទេស សូមមេត្តា រួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដោយមិនប្រកាន់និន្នាការនយោបាយឬឋានៈសង្គម ក្នុងស្មារតី "ខ្មែរតែមួយ" ចូលរួមធ្វើមហាបាតុកម្មអហិង្សាជាមួយយើងខ្ញុំ ចាប់ពីម៉ោង៨ព្រឹករហូតម៉ោង៥ល្ងាចចំនួន៣ថ្ងៃជាប់គ្នាគឺនៅថ្ងៃទី១១-១២-១៣ខែសីហា ឆ្នាំ២០១៤។

ថ្ងៃទី១- (១១-០៨-២០១៤) ម៉ោង០៨ព្រឹកយើងខ្ញុំនឹងជួបជុំគ្នាប្រមាណ១០០០នាក់ នៅសួនច្បារមុខវត្តបុទុមវតី(អតីតរោងអាយ៉ៃ) សម្តែងមតិរហូតដល់ម៉ោង០១រសៀល ដង្ហែញត្តិទៅក្រសួងការបរទេស និងសហប្រតិការបត្តិអន្តរជាតិ ទៅស្ថានទូត ភូមា និងសាធារណរដ្ឋប្រជាមានិតឡាវរួច ដង្ហែក្បួនទៅស្ថានទូតវៀតណាម ដើម្បីទទួលចម្លើយអំពីការទទួលញត្តិរបស់យើងខ្ញុំ និងរំសាយនៅម៉ោង៥ល្ងាច។


ទីស្នាក់ការផ្ទះលេខ៖ ៧២ ផ្លូវលេខ ៤២៦A, ភូមិគោតឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ /៩៣ ៩៧ ៩៧ ០៦
E-mail: thachsetha13@gmail.com Website: www.khmerkromngo.org

ថ្ងៃទី២- (១២-០៨-២០១៤)ម៉ោង០៨ព្រឹក យើងនឹងជួបជុំគ្នានៅសួនច្បារមុខវត្តបុទុមវតី (អតីតរោងអាយ៉ៃ) សម្តែងមតិរហូតដល់ម៉ោង១រសៀល ដង្ហែញត្តិទៅស្ថានទូត សាំងហ្គាពួរ ប្រុយណេ ថៃឡង់ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី រួចដង្ហែក្បួនទៅស្ថានទូតវៀតណាម ដើម្បីទទួលចម្លើយ អំពី ការទទួលញត្តិ របស់យើង និងរំសាយ នៅម៉ោង៥ល្ងាច។

ថ្ងៃទី៣- (១៣-០៨-២០១៤) ម៉ោង០៨ព្រឹក យើងនឹងជួបជុំគ្នានៅសួនច្បារមុខវត្តបុទុមវតី(អតីតរោងអាយ៉ៃ) សម្តែងមតិរហូតដល់ម៉ោង១រសៀល ដង្ហែញត្តិទៅ ស្ថានទូត ហ្វីលីពីន រួចដង្ហែក្បួនទៅស្ថានទូតវៀតណាម ដើម្បីទទួលចម្លើយអំពីការទទួលញត្តិរបស់យើងខ្ញុំ និងរំសាយ នៅម៉ោង៥ល្ងាច។

យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមជាតិ យុវជន យុវនារី និងលះបង់ពេលវេលាដ៏មានតម្លៃ និមន្តនិងអញ្ជើញចូលរួមជាក់ជាមិនខាន។

វត្តមានរបស់ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមជាតិ យុវជន យុវនារី គឺជាការបង្ហាញនូវសាមគ្គីភាពដ៏រឹងមាំនៃមហាគ្រួសារខ្មែរ ក្នុងការប្តេជ្ញាការពារប្រវត្តិសាស្ត្រខ្មែរ កិត្តិយសពូជសាសន៍ខ្មែរ និងការពារទឹកដីខ្មែរយ៉ាងពិតប្រាកដ ជាពិសេស បង្ហាញឲ្យរដ្ឋាភិបាលវៀតណាមឃើញច្បាស់ថា ព្រះសង្ឃខ្មែរ ប្រជាជាតិខ្មែរ មិនអាចនៅស្ងៀមឈរអោបដៃឲ្យរដ្ឋាភិបាលវៀតណាម ក្រឡៃប្រវត្តិសាស្ត្រខ្មែរ មើលងាយប្រជារាស្ត្រខ្មែរតាមអំពើចិត្តនោះទេ។

សូមព្រះករុណាគ្រប់ព្រះអង្គ ទទួលនូវការគោរព ស្រឡាញ់ និងរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំព្រះករុណាខ្ញុំ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

អតីតសមាជិកព្រឹទ្ធសភា

ទីស្នាក់ការផ្ទះលេខ៖ ៧២ ផ្លូវលេខ ៤២៦A, ភូមិគោគឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ /៩៣ ៩៧ ៩៧ ០៦

E-mail: thachsetha13@gmail.com Website: www.khmerkromngo.org